# តុលាការកំពូលសម្រេចលុបចោលដីកាបំបែកសំណុំរឿង០០២ របស់អង្គជំនុំជម្រះសាលាដំបូង

*ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៣*

*លីម ជ័យទ័ត្ត, អ្នកសង្កេតការណ៍ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម*

*មជ្ឈមណ្ឌលឯកសារកម្ពុជា*

*ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣ អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចេញសេចក្តីសម្រេចមួយលុបចោលដីកាបំបែកសំណុំរឿងរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានធ្វើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ឲ្យទៅជាផ្នែកតូចៗ កាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១កន្លងទៅ ។ សេចក្តីសម្រេចនេះធ្វើឡើងបន្ទាប់ពីមានពាក្យបណ្តឹងរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១២ ស្នើសុំអង្គជំនុំជម្រះតុលាការកំពូលឲ្យធ្វើការកែតម្រូវនូវដីកាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង និងស្នើឲ្យមានការពង្រីកវិសាលភាពនៃសំណុំរឿង០០២/០១ ដោយដាក់បញ្ចូលបន្ថែមនូវអង្គហេតុពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលបានកើតឡើងនៅតំបន់១២ និងនៅមន្ទីរស-២១ ដើម្បីជាប្រយោជន៍នៃយុត្តិធម៌ ។*

*នៅក្នុងសេចក្តីសម្រេចនេះ អង្គជំនុំជម្រះតុលាការកំពូលបានរកឃើញថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តនូវកំហុសទាក់ទងនឹងអង្គច្បាប់ ក្នុងការបកស្រាយដែននៃយុត្តាធិការរបស់ខ្លួនអនុលោមតាមវិធាន៨៩ស្ទួនពីរ នៃវិធានផ្ទៃក្នុង ដែលការបកស្រាយនោះពុំបានគិតអំពីភាពចាំបាច់ក្នុងការបង្ហាញជាសំអាងហេតុគ្រប់គ្រាន់នូវអត្ថប្រយោជន៍យុត្តិធម៌ក្នុងការបំបែកសំណុំរឿង០០២ ក៏ដូចជាភាពចាំបាច់ក្នុងការស្តាប់ភាគីនានាស្តីពីលក្ខខណ្ឌនៃការបំបែកនីតិវិធី ។ អង្គជំនុំជម្រះតុលាការកំពូលបានចាត់ទុកការប្រើប្រាស់ឆន្ទានុសិទ្ធិក្នុងការបកស្រាយដែនយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូងថា បានរំលោភលើសិទ្ធិរបស់ភាគីក្នុងការទទួលបានយោបល់ដែលមានសំអាងហេតុ និងការជំនុំជម្រះ ។ ម្យ៉ាងវិញទៀត ការណ៍ដែលអង្គជំនុំជម្រះសាលាដំបូង ខកខានពុំបានបង្កើតផែនការទាក់ទងនឹងការដោះស្រាយសំណុំរឿងដែលនៅសេសសល់ដើម្បីយកមកជំនុំជម្រះក្នុងសំណុំរឿង០០២ ក៏បានធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ភាគីដែរ ។*

ទោះបីជាអង្គជំនុំជម្រះតុលាការកំពូលបានទទួលស្គាល់អំពីភាពចាំបាច់របស់អង្គជំនុំជម្រះសាលាដំបូងក្នុងការបំបែកកិច្ចដំណើរការនីតិវិធីដោយសារតែវិសាលភាព និងភាពស្មុគស្មាញនៃសំណុំរឿង០០២ រួមទាំងស្ថានភាពសុខភាពរបស់ជនជាប់ចោទដែលកាន់តែធ្លាក់ចុះជាបន្តបន្ទាប់ ប៉ុន្តែអានុភាពនៃកំហុសរបស់អង្គជំនុំជម្រះសាលាដំបូង គឺតម្រូវឱ្យត្រូវតែមានការលុបចោលដីកាបំបែកកិច្ចដំណើរការនីតិវិធី សេចក្តីសម្រេចស្តីពីការពិចារណាឡើងវិញ និងអនុស្សរណៈពាក់ព័ន្ធទាំងឡាយ ។ ហេតុនេះ សំណើសុំរបស់សហព្រះរាជអាជ្ញាឱ្យកែប្រែសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីដាក់បញ្ចូលអង្គហេតុពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មនៅស្រុក១២ និងនៅមន្ទីរស-២១ទៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០១ ក៏ត្រូវចាត់ទុកជាអាសាបង់ដែរ ។

ថ្វីត្បិតមានការសម្រេចលុបចោលដីកាបំបែកកិច្ចដំណើរការនីតិវិធីក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលអះអាងថា ការលុបចោលនេះនឹងពុំប៉ះពាល់ដល់ការវាយតម្លៃឡើងវិញរបស់អង្គជំនុំជម្រះសាលាដំបូងលើការបំបែកសំណុំរឿង០០២ ដែលមានចែងនៅក្នុងវិធាន៨៩ស្ទួនពីរនៃវិធានផ្ទៃក្នុងឡើយ ។ បន្ថែមពីលើនេះ អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់អនុសាសន៍ថា ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងនៅតែបន្តពិចារណាលើអត្ថប្រយោជន៍យុត្តិធម៌ ដែលតម្រូវឱ្យត្រូវតែបំបែកសំណុំរឿង០០២មែននោះ ជាដំបូងអង្គជំនុំជម្រះសាលាដំបូងត្រូវអញ្ជើញភាគីនានាដាក់សារណាដើម្បីស្តាប់មតិយោបល់របស់ភាគីទាក់ទងនឹងលក្ខខណ្ឌនៃការបំបែកនីតិវិធីលើសំណុំរឿង០០២ ។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះសាលាដំបូងគប្បីរៀបចំផែនការច្បាស់លាស់ និងជាក់ស្តែងសម្រាប់ការជំនុំជម្រះលើបទចោទទាំងមូលនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។ ពោលគឺ ពុំមែនជាការរៀបចំផែនការសម្រាប់តែសវនាការផ្នែកតូចនោះទេ ។ នៅក្នុងករណីដែលស្ថានភាពសុខភាពរបស់ជនជាប់ចោទកាន់តែចុះដុនដាបទៅៗ អង្គជំនុំជម្រះសាលាដំបូងអាចប្រើប្រាស់នូវមធ្យោបាយដែលល្អប្រសើរក្នុងការផ្តល់យុត្តិធម៌ គឺត្រូវធ្វើឡើងតាមរយៈការចេញសាលក្រម ទោះបីជាការជំនុំជម្រះនោះធ្វើឡើងត្រឹមតែផ្នែកណាមួយនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះក៏ដោយ ។ ប៉ុន្តែត្រូវមានការបញ្ជាក់ច្បាស់លាស់ និងផ្តល់ការពិចារណាសមស្របចំពោះការតំណាងសមហេតុផលនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទៅជាការជំនុំជម្រះតូចជាងនេះ ។

អង្គជំនុំជម្រះតុលាការកំពូលក៏បានផ្តល់ជាដំណោះស្រាយថា ក្នុងករណីមានការបន្តការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ អង្គជំនុំជម្រះវិសាមញ្ញមួយនេះ គប្បីបង្កើតឱ្យមានអង្គចៅក្រមជំនុំជម្រះមួយបន្ថែមទៀត ដើម្បីគាំទ្រដល់ការជំនុំជម្រះឱ្យបានទាន់ពេលវេលាលើផ្នែកដែលនៅសេសសល់នៃសំណុំរឿង០០២ ។ ម្យ៉ាងវិញទៀត អង្គចៅក្រមជំនុំជម្រះទី២នេះ នឹងការពារបានចំពោះការព្រួយ

បារម្ភទាក់ទងនឹងភាពលំអៀងដែលទំនងជាមាន បណ្ដាមកពីចៅក្រមដែលចូលរួមកាត់សេចក្ដីនៅក្នុងការជំនុំជម្រះទីមួយ ហើយបន្តទៅកាត់សេចក្ដីនៅក្នុងការជំនុំជម្រះទីពីរ ។ អង្គជំនុំជម្រះតុលាការកំពូលបានផ្ដល់អនុសាសន៍ទៀតថា អង្គជំនុំជម្រះសាលាដំបូងទីពីរនេះ អាចចាប់ផ្ដើមកិច្ចដំណើរការនីតិវិធីរបស់ខ្លួនភ្លាមៗ នៅខណៈពេលដែលអង្គជំនុំជម្រះសាលាដំបូងកំពុងជាប់រវល់ជាមួយនឹងការព្រាងសាលក្រមក្នុងសំណុំរឿង ០០២/០១ ដោយធានាបានថា ភាគីមិនទុកពេលឲ្យទំនេរក្នុងអំឡុងពេលនោះ ។ ការដំណើរការសវនាការជារៀងរាល់ថ្ងៃ តាមដែលអាចធ្វើទៅបាន គឺជាការធានាចំពោះលទ្ធភាពក្នុងការសម្រេចជាស្ថាពរលើបទចោទដែលនៅសេសសល់ឲ្យបានឆាប់រហ័ស ព្រោះជនជាប់ចោទមានវ័យកាន់តែចាស់ជរា និងមានបញ្ហាសុខភាពកាន់តែដុនដាប រួមទាំងចោទប្រកាន់ដែលនៅសេសសល់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។

សូមបញ្ជាក់ថា ចាប់តាំងពីមានការបំបែកសំណុំរឿង០០២ទៅជាផ្នែកតូចៗ អង្គជំនុំជម្រះសាលាដំបូងបានចំណាយពេល១៥៥ថ្ងៃនៃសវនាការ ដើម្បីស្ដាប់សក្ខីកម្មរបស់សាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញ ក្នុងសំណុំរឿង០០២/០១ ។ ក្នុងសំណុំរឿង០០២/០១នេះ អង្គជំនុំជម្រះសាលាដំបូងបានលើកយកការចោទប្រកាន់លើអង្គហេតុមួយចំនួនដើម្បីបើកសវនាការ ។ ការចោទប្រកាន់លើអង្គហេតុទាំងនោះរួមមាន៖

ក) រចនាសម្ព័ន្ធនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

ខ) តួនាទីរបស់ជនជាប់ចោទម្នាក់ៗ នៅមុនពេលមានការបង្កើតរបបកម្ពុជាប្រជាធិបតេយ្យ និងនៅពេលជនជាប់ចោទម្នាក់បានទទួលការចាត់តាំងនូវតួនាទីទាំងនោះ ។

គ) តួនាទីរបស់ជនជាប់ចោទម្នាក់ៗក្នុងជួររដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ការទទួលខុសត្រូវរបស់ពួកគេតាមការចាត់តាំង ក្របខណ្ឌនៃសិទ្ធិអំណាចរបស់ពួកគេ និងខ្សែបណ្ដាញទាក់ទងនៅក្នុងរយៈកាលដែលពាក់ព័ន្ធ និងយុត្តាធិការតាមពេលវេលារបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

ឃ) គោលនយោបាយនៃរបបកម្ពុជាប្រជាធិបតេយ្យស្ដីពីបញ្ហាទាំងឡាយដែលបានលើកឡើងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។

ង) ការចោទប្រកាន់លើអង្គហេតុ ដែលបានរៀបរាប់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជននៅក្នុងដំណាក់កាលទី១ និងដំណាក់កាលទី២ ។

ច) ការសម្លាប់អតីតទាហាន លន់ នល់ និងមន្ត្រីរដ្ឋការនៅទួលពោធិ៍ជ្រៃ ។

រហូតមកដល់ពេលនេះ អង្គជំនុំជម្រះបាននឹងកំពុងបើកសវនាការជំនុំជម្រះទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជននៅក្នុងដំណាក់កាលទី១ និងដំណាក់កាលទី២ និងការសម្លាប់អតីតទាហាន លន់ នល់ និងមន្ត្រីរដ្ឋការនៅទួលពោធិ៍ជ្រៃ ។

អង្គជំនុំជម្រះសាលាដំបូងគ្រោងនឹងបញ្ចប់សំណុំរឿង០០២/០១ នៅត្រឹមបំណាច់ឆ្នាំ២០១៣ ប៉ុន្តែការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលុបចោលដីកាបំបែកសំណុំរឿងនាពេលនេះ នឹងក្លាយជារបត់ថ្មីមួយសម្រាប់អង្គជំនុំជម្រះសាលាដំបូង ។